# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តបាត់ដំបង
លេខ: ០០៩ /២០ សរណន

## សេចក្តីណែនាំ
## ស្តីពី
## ការទប់ស្កាត់ការឆ្លងមេរោគកូវីដ-១៩ (COVID-19) នៅក្នុងសហគមន៍នៅខេត្តបាត់ដំបង

**យោង៖** - អនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** នាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ។

- ស្មារតីកិច្ចប្រជុំចង្អៀតគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ (COVID-19) ខេត្តបាត់ដំបង នាថ្ងៃចន្ទ ១៥កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ នៅសាលាខេត្តបាត់ដំបង

រដ្ឋបាលខេត្តបាត់ដំបង សូមធ្វើការណែនាំដល់រដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុងខេត្ត មន្ទីរ-អង្គភាពជំនាញជុំវិញខេត្ត ពាណិជ្ជករ អាជីវករ សេវាករ និងបងប្អូនប្រជាពលរដ្ឋជ្រាបថា៖ ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលមេរោគកូវីដ-១៩ (COVID-19) នៅក្នុងសហគមន៍នៅខេត្តបាត់ដំបង រដ្ឋបាលខេត្តសូមធ្វើការណែនាំវិធានការបង្ការ និងទប់ស្កាត់ដូចខាងក្រោម៖

១- ត្រូវធ្វើការផ្អាករាល់ការជួបជុំ ឬការប្រមូលផ្តុំ ឬកម្មវិធីដែលមានមនុស្សច្រើនចាប់ពីថ្ងៃនេះរហូតដល់ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ ។

២- អនុញ្ញាតឱ្យមានការជួបជុំមិនឱ្យលើសពី២០នាក់ (ក្នុងករណីចាំបាច់) ប៉ុន្តែការជួបជុំនេះត្រូវរក្សាគម្លាតសុវត្ថិភាពសង្គម យ៉ាងតិច១,៥ម៉ែត្រ ពីម្នាក់ទៅម្នាក់ ។

៣- ត្រូវចាត់តាំង មន្ត្រី និងកងកម្លាំង សហការជាមួយ អាជ្ញាធរមូលដ្ឋាននីមួយៗ ដើម្បីធ្វើការផ្សព្វផ្សាយ អប់រំ និងណែនាំដល់បងប្អូនប្រជាពលរដ្ឋ ដែលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោល **"ព្រឹត្តិការណ៍សហគមន៍២៨ វិច្ឆិកា "** ឱ្យទៅធ្វើតេស្តរកមេរោគកូវីដ-១៩ (COVID-19) ។ ករណីលទ្ធផលតេស្តអវិជ្ជមាន ត្រូវធ្វើចត្តាឡីស័កតាមការណែនាំរបស់ក្រុមគ្រូពេទ្យ មន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្ត ។

៤- ត្រូវចុះត្រួតពិនិត្យ និងតាមដាននៅតាមភោជនីយដ្ឋាន អាហារដ្ឋាន កន្លែងលក់ដូរនានា និងនៅតាមសណ្ឋាគារ ផ្ទះសំណាក់. . .។ល។ ឱ្យអនុវត្តវិធានការបង្ការ និងទប់ស្កាត់ការរីករាលដាលមេរោគកូវីដ-១៩(COVID-19) ក្នុងនោះម្ចាស់អាជីវកម្មទាំងអស់ខាងលើត្រូវរៀបចំអាកុល ឬជែលលាងដៃ នៅខាងមុខច្រកទ្វារចេញ-ចូល និងត្រូវចាត់តាំងបុគ្គលិកឱ្យធ្វើការវាស់កម្តៅភ្ញៀវទាំងអស់ ជាមួយការពាក់ម៉ាស់ជូរ រក្សាគម្លាតសុវត្ថិភាពសង្គមមុននឹងអនុញ្ញាតឱ្យចូលទីតាំងអាជីវកម្មទាំងនោះ ព្រមទាំងត្រូវរៀបចំរក្សាគម្លាតសុវត្ថិភាពសង្គមយ៉ាងតិច១,៥ម៉ែត្រ ពីម្នាក់ទៅម្នាក់ក្នុងពេលអង្គុយ ។ ក្នុងករណីដែលម្ចាស់ទីតាំងអាជីវកម្មខាងលើមិនអនុវត្តតាមការណែនាំទេនោះរដ្ឋបាលខេត្តបាត់ដំបង នឹងបិទអាជីវកម្មជាបណ្តោះអាសន្ន ។



អាសយដ្ឋាន: ផ្លូវលេខ០១, ទល់មុខស្ពានចាស់, ទូរស័ព្ទនិងទូរសារលេខ: ០៥៣ ៧៣៩ ៩៩៩ / ៧៣៩ ៩៩៩ គេហទំព័រ: www.battambang.gov.kh
Address : Road 01, In front of old bridge, Telephone & Fax : 053 739 999 / 739 999 Website: www.battambang.gov.kh
Facebook Page : រដ្ឋបាលខេត្តបាត់ដំបង : www.Facebook.com.com: www.battambang.gov.kh

៥- ត្រូវចុះត្រួតពិនិត្យ និងតាមដានការអនុវត្តនូវវិធានការផ្អាកជាបណ្ដោះអាសន្ននូវទីតាំងអាជីវកម្មមួយចំនួនដូចជា ក្លឹបហាត់ប្រាណ រោងភាពយន្ត សារមន្ទីរ ខារ៉ាអូខេ (KTV) ក្លឹបកម្សាន្ត (រង្គសាល បៀរហ្គាឌិន) អាជីវកម្មម៉ាស្សាសុខភាព និងស្ប៉ា ។

៦- ចុះពិនិត្យស្ថានភាពនៅទីកន្លែងស្នាក់នៅរបស់បងប្អូនប្រជាពលរដ្ឋធ្វើចត្តាឡីស័កតាមផ្ទះ ដែលបញ្ជូនមកពីមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក និងពិនិត្យស្ថានភាពបងប្អូនប្រជាពលរដ្ឋដែលស្ម័គ្រចិត្តធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័កទាំងអស់ ដែលរៀបចំដោយរដ្ឋបាលខេត្តបាត់ដំបង និងត្រូវរៀបចំចាត់ចែងការងារបន្ត ដោយផ្អែកលើលទ្ធផលនៃការតាមដានសុខភាព ។

៧- អំពាវនាវដល់បងប្អូនប្រជាពលរដ្ឋ ក្នុងករណីមិនចាំបាច់មិនត្រូវធ្វើដំណើរចេញក្រៅផ្ទះ ។ ក្នុងករណីដែលមានតម្រូវការចាំបាច់ជៀសមិនផុត ត្រូវអនុវត្តវិធានការសុខាភិបាលឱ្យបានម៉ឺងម៉ាត់បំផុត ។

៨- រដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុងខេត្ត និងមន្ទីរ-អង្គភាពជំនាញជុំវិញខេត្តត្រូវធ្វើការផ្អាករាល់ការប្រជុំចាប់ពីពេលនេះរហូតដល់ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ ។ ចំពោះទីតាំងផ្ដល់សេវាសាធារណៈ និងសេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយ ឬតាមអង្គភាពច្រកចេញចូលតែមួយ ការិយាល័យច្រកចេញចូលតែមួយព្រមទាំងការផ្ដល់សេវានានារបស់គ្រឹះស្ថានឯកជនទាំងអស់ក្នុងខេត្ត ក្នុងការផ្ដល់ជូនប្រជាពលរដ្ឋ ឬអតិថិជនត្រូវរៀបចំចាំបាច់ឱ្យមានការវាស់កម្ដៅ ការពាក់ម៉ាស់ការលាងសម្អាតដៃជាមួយសាប៊ូ និងទឹកស្អាត ឬអាកុល ឬជែលលាងដៃ និងរៀបចំកន្លែងអង្គុយចម្ងាយ១,៥ម៉ែត្រពីម្នាក់ទៅម្នាក់ដោយកំណត់ចំនួនប្រជាពលរដ្ឋដែលមកទទួលសេវាមិនឱ្យលើសពី២០នាក់ ក្នុងពេលតែមួយ ។

៩- ចំពោះផ្សាររដ្ឋ និងផ្សារឯកជន ត្រូវរៀបចំឱ្យមានការវាស់កម្ដៅ ការពាក់ម៉ាស់ និងការលាងសម្អាតដៃជាមួយសាប៊ូ និងទឹកស្អាត ឬអាកុល ឬជែលលាងដៃ ព្រមទាំងអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវការរក្សាគម្លាតសុវត្ថិភាពសង្គម ។

១០- ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវវិធានការបង្ការ និងទប់ស្កាត់ការីករាលដាលមេរោគកូវីដ-១៩ (COVID-19) ផ្សេងៗទៀតរបស់ក្រសួងសុខាភិបាល និងស្ថាប័នពាក់ព័ន្ធនានា ដែលកំពុងនៅជាធរមាន ។

ទទួលបានសេចក្ដីណែនាំនេះ សូមរដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុងខេត្ត មន្ទីរ-អង្គភាពជំនាញជុំវិញខេត្ត ពាណិជ្ជករ អាជីវករ សេវាករ និងបងប្អូនប្រជាពលរដ្ឋទាំងអស់ ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

រដ្ឋបាលខេត្តបាត់ដំបងសង្ឃឹមយ៉ាងមុតមាំលើស្មារតីយោគយល់អធ្យាស្រ័យខ្ពស់បំផុត ពីសំណាក់បងប្អូនប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន និងសូមចូលរួមអនុវត្តឱ្យបានម៉ឺងម៉ាត់នូវសេចក្ដីណែនាំខាងលើកុំបីខាន ។

ថ្ងៃចន្ទ ១៥កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
បាត់ដំបង ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០
អភិបាលខេត្ត

ងួន រតនៈ

*ចម្លងជូន៖*
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួង ស្ថាប័នពាក់ព័ន្ធ

"ដើម្បីគោរពជូនជ្រាប"
- ស្នងការដ្ឋាននគរបាលខេត្ត
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត
- មន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្ត
- មន្ទីរទេសចរណ៍ខេត្ត
- រដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុងខេត្ត
- គ្រប់មន្ទីរ អង្គភាពពាក់ព័ន្ធជុំវិញខេត្ត

"ដើម្បីសហការអនុវត្ត"
- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ

"ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ